គណកម្មការពលករ
COMITE VIE OUVRIERE
ព្រះសហគមន៍កាតូលិកភ្នំពេញ
VICARIAT APOSTOLIQUE DE PHNOM PENH

សង្ខេបពត៌មាន

**REVUE DE PRESSE**
**8/16**

## លោក វន់ពៅ ស្នើឲមានកំណត់ប្រាក់គោល និងថ្ងៃឈប់សម្រាកសម្រាប់កម្មករធ្វើការតាមផ្ទះ

ភ្នំពេញ៖ លោក វន់ ពៅ បានជំរុញឲ រដ្ឋាភិបាលធ្វើវិសោធនកម្មតាផ្ទះ។ លក្ខខណ្ឌការងារទាំងនោះមានដូចជាការកំណត់ប្រាក់ខែគោល និងថ្ងៃឈប់សម្រាកជាដើម។ បើតាម លោក វន់ ពៅ កម្មករបម្រើការងារតាមផ្ទះ ក៏ត្រូវទទួលបានអត្ថប្រយោជន៍ និងការគោរពសិទ្ធិ ដូចកម្មករកាត់ដេរដែរ។

លោក វន់ ពៅ ប្រធានសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ បានស្នើឲរដ្ឋាភិបាលធ្វើវិសោធនកម្មច្បាប់ការងារ ដើម្បីកំណត់លក្ខខ័ណ្ឌការងារ សម្រាប់កម្មករបម្រើការងារតាមផ្ទះ។

លោកមានប្រសាសន៍ថា ការកំណត់លក្ខខណ្ឌការងារសម្រាប់អ្នកបម្រើការងារតាមផ្ទះពិតជាចាំបាច់ណាស់ ដើម្បីអត្ថប្រយោជន៍ផ្សេងៗដល់ពួកគេទាំងនោះ។

បើតាមលោក វន់ ពៅ កម្មករធ្វើការតាមផ្ទះគួរទទួលបានលក្ខខណ្ឌការងារ ដូចជា ការកំណត់ប្រាក់ខែគោល ការឈប់សម្រាកប្រចាំសប្តាហ៍ និងការកំណត់ម៉ោងធ្វើការត្រឹម ៨ ម៉ោងជាដើម។

លោកថ្លែងប្រាប់សារព័ត៌មានថ្មីៗយ៉ាងដូច្នោះថា៖ " អ្នកទាំងនោះក៏ជាកម្មករដែរ ដូច្នោះរដ្ឋត្រូវបំពេញនូវអ្វីជាសេចក្តីត្រូវការរបស់ពួកគាត់ ហើយម៉្យាងទៀតកម្មករបម្រើការងារតាមផ្ទះក៏មានចំនួនច្រើនផងដែរ ដូច្នេះគួរកំណត់ប្រាក់ឈ្នួលគោលសម្រាប់ពួកគាត់"។

ប្រធានសមាគមរូបនេះ បន្តដោយលើកឡើងពីស្ថានភាពប្រាក់ខែរបស់អ្នកបម្រើការងារតាមផ្ទះ ដែលស្រាវជ្រាវដោយសង្គមស៊ីវិល នៅក្នុងឆ្នាំ២០១៣ កន្លងទៅ។ បើតាម លោកប្រាប់ កម្មករបម្រើការងារតាមផ្ទះនៅទូទាំងប្រទេសមានចំនួនប្រមាណ ២៤ម៉ឺននាក់ ក្នុងនោះស្ត្រីមានចំនួនដល់ទៅ ៨០ភាគរយ ដោយជាមធ្យមកម្មករម្នាក់ៗទទួលបានប្រាក់ខែ៥០ដុល្លា។

លោកបន្តថា អ្នកបម្រើការងារចំនួន ១៤ភាគរយ មានប្រាក់ខែពី៧០ភាគរយទៅ១០០ដុល្លា ដែលជាប្រាក់ខែខ្ពស់បំផុត ខណៈកម្មករ៦០ភាគរយទទួលប្រាក់ខែទាបជាង៥០ដុល្លា។ ក្រៅពីបញ្ហាប្រាក់ខែទាប កម្មករធ្វើការតាមផ្ទះចំនួន៩០ភាគរយ ត្រូវធ្វើការ៧ថ្ងៃក្នុង១សប្តាហ៍ ហើយពួកគេមួយចំនួនធ្វើការលើសពី៨ម៉ោងក្នុងមួយថ្ងៃ។ នេះជាការអះអាងរបស់លោក វន់ ពៅ។

## រោងចក្រមួយបិទទ្វារ ដោយសារគ្មានអ្នកបញ្ជាទិញ

ភ្នំពេញ៖ រោងចក្រ H&L Apparel ( Cambodia ) ដែលមានទីតាំងនៅសង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ បានប្រកាសប្រកាសបិទក្រុមហ៊ុន ដោយសារអ្នកបញ្ជាទិញទំនិញក្រោយពីរោងចក្រមួយនេះបានដំណើរការជាង ៤ ឆ្នាំនៅកម្ពុជា តែខាងក្រុមហ៊ុនបានព្រមព្រៀងប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ផ្សេងៗដល់កម្មករជាង ៤០០នាក់។

លោក ស៊ុត ចិត្រ មន្ត្រីសហជីពចលនាកម្មករកម្ពុជាបានឲដឹងថា កម្មករបាននាំតវ៉ារយៈពេលពីរថ្ងៃដើម្បីទាមទារប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ហើយកាលពីម្សិលមិញក្រុមហ៊ុនបានចរចារ និងសម្រេចបើកឲកម្មករគ្រប់ៗគ្នា។

លោកបានបន្តថានៅថ្ងៃទី ១៥ សីហា ខាងក្រុមហ៊ុនថាបើកឲកម្មករដែលមានកិច្ចសន្យារយៈពេលវែង និងអ្នកធ្វើការយូរឆ្នាំហើយ រីឯនៅថ្ងៃទី១៩ សីហា ក្រុមហ៊ុននឹងបើកជូនកម្មករដែលមានរយៈពេលខ្លី។

លោកថា៖ “ កម្មករតវ៉ាពីរថ្ងៃក្រោយមកក្រុមហ៊ុនចរចារសម្រេចបើកឲកម្មករទាំងអស់តែអ្វីដែលគួរឲស្តាយ កម្មករ ៤០០ នាក់អត់មានការងារធ្វើ” ។

កម្មករម្នាក់ឈ្មោះ អេង សម្បត្តិ បានឲដឹងថា ខាងក្រុមហ៊ុនបានជូនដំណឹងខាងកម្មករពីការបិទរោងចក្រមួយនេះនៅថ្ងៃទី ០៩ សីហា ហើយនៅថ្ងៃទី ១៣ សីហាក្រុមហ៊ុនក៏ចាប់ផ្តើមបិទតែម្តង។

កម្មកររូបនោះបានថ្លែងថា៖ “ រកការងារភ្លាមៗមិនបានទេកម្មករដល់ទៅ ៤០០ នាក់ពួលគេពិបាករកការងារធ្វើណាស់ ” ។

លោក ផៅ ដូ ប្រធានរដ្ឋបាលរោងចក្រ H&L បានឲដឹងថាខាងក្រុមហ៊ុនព្រមដោះស្រាយជូនកម្មករសម្រាប់បួកគាត់ជាង ៤០០ នាក់។

លោកថា៖ “ អ្នក buyer ធំគ្មានការកម្ម៉ង់ទំនិញយើងអត់មាន buyer ទៀតអញ្ជឹងក្រុមហ៊ុនប្រកាសបិទតែម្តងតែរឿងប្រាក់ឈ្នួល និងប្រាក់ផ្សេងៗទៀតក្រុមហ៊ុនដោះស្រាយជូនទាំងអស់ ”។

## AmCham: បរិយាកាសវិនិយោគកម្ពុជានៅតែវិជ្ជមាន

ភ្នំពេញ៖ ទោះបីជាមានឧបសគ្គមួយចំនួនសម្រាប់វិនិយោគិនអាមេរិចចូលកម្ពុជាដែលរួមមានអំពើពុករលួយ កម្សោយខាងច្បាប់ និងតំលៃអគ្គិសនីខ្ពស់ក៏ដោយ ក៏លោក Bretton Sciaroni ប្រធានសភាពាណិជ្ជកម្មអាមេរិចប្រចាំកម្ពុជាមានសុទិដ្ឋិនិយមជាអាត្រាកំនើនគួរឲចាប់អារម្មណ៍របស់កម្ពុជានឹងបន្តជួយដល់ក្រុមហ៊ុនដែលវិនិយោគនៅទីនេះទទួលបាន

លោកលើកឡើងថា៖ “ វាមិនមែនមានអាថ៌កំបាំងទេដែលយើងទទួលបានកំនើន ៧ ភាគរយក្នុងមួយឆ្នាំ ហើយក្រុមហ៊ុនអាមេរិចបន្តចូលមកទីនេះ ” ។

លោកថ្លែងថា៖ “ កម្ពុជានៅតែមានញ្ហា និងមិនមែនទីតាំងដ៏រាក់ទាក់សម្រាប់អាជីវកម្ម ១០០ ភាគរយនោះទេ ”។ ប៉ុន្តែលោកបន្ថែមថាកម្ពុជានៅតែទទួលបានអត្ថប្រយោជន៍នៃគោលនយោបាយរបស់ខ្លួនដែលបានបង្កើតឡើងក្នុងន័យនេះវា “ ប្រហែលជាទីផ្សាសេរីខ្លាំងបំផុតក្នុងចំណោមបណ្តាប្រទេសអាស៊ីអាគ្នេយ៍ទាំងអស់ ” ។

ការកត់សម្គាល់នេះធ្វើឡើងបន្ទាប់ពីការចេញផ្សាយថ្មីៗពីការអង្កេតចក្ខុវិស័យអាជីវកម្មអាស៊ានឆ្នាំ ២០១៧ បានចេញកាលពីដើមខែនេះដោយសភាពាណិជ្ជកម្មអាមេរិចប្រចាំប្រទេសសិង្ហបុរី និងសភាពាណិជ្ជកម្មអាមេរិចដែលបានបញ្ជាក់ថា ៨៨ ភាគរយគ្រោងនឹងពង្រីកប្រតិបត្តិការអាជីវកម្មរបស់ពួកគេ។

ការអង្កេតដែលរួមមានការឆ្លើយតបពីសមាជិក ២៦ ក្នុងចំណោមសមាជិក ៩៨ របស់សភាពាណិជ្ជកម្មអាមេរិចនៅកម្ពុជាបានកត់សម្គាល់ថាការកែលំអបន្ទាប់បន្សំនៅក្នុងការយល់ឃើញពីរបៀបសូកប៉ាន់ក្រៅផ្លូវការដល់មន្ត្រីរដ្ឋាភិបាលប៉ះពាល់ដល់បរិយាកាសអាជីវកម្មបើធៀបនឹងការអង្កេតពីឆ្នាំមុន។

លោក Sciaroni លើកឡើងថា៖ “អំពើពុករលួយនៅតែជាបញ្ហាមួយ ប៉ុន្តែខ្ញុំសរសើរដល់រដ្ឋាភិបាលសម្រាប់អ្វីដែលពួកគេបាននឹងកំពុងធ្វើ ”។

លោកកត់សម្គាល់ជាពិសេសថាលោក ឡាយ ថារ័ត្ន មន្ត្រីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវបានចោទប្រកាន់កាលពីថ្ងៃសុក្រមុន ពីបទទួលមូលនិធិខុសច្បាប់បន្ទាប់ពីត្រូវបានចាប់ខ្លួនកាលពីខែឧសភា។

ប៉ុន្តែការជាប់គាំងដ៏ធំដែលរាំងស្ទះដល់ការពង្រីកអាជីវកម្មនៅតែមានការលំបាកនៅក្នុងការស្វែងរកកំលាំងពលកម្មជំនាញខ្ពស់ខណៈការពេញចិត្តពីភាពដែលអាចរកបានកម្លាំងពលកម្មមានប្រាក់ឈ្នួលទាបបានធ្លាក់ចុះពីអាត្រា ៦៧ ភាគរយកាលពីឆ្នាំមុនមកនៅត្រឹម ៥០ ភាគរយនៅឆ្នាំនេះ។

របាយការណ៍បង្ហាញថា៖ “ អ្នកឆ្លើយតបជាទូទៅស្ថិតនៅកណ្តាលចំពោះភ្នាក់ងាររដ្ឋាភិបាលនៅប្រទេសកម្ពុជា។ មិនមានភ្នាក់ងារណាមួយទទួលបានអត្រាការពេញចិត្តខ្ពស់ជាង ៥០ ភាគរយ ឬអត្រាមិនពេញចិត្តខ្ពស់ជាង ៤០ ភាគរយទេ” ។

ខណៈដែលក្រុមហ៊ុនអាមេរិចនៅក្នុងប្រទេសកម្ពុជាបានមើលឃើញសក្តានុពលធំជាងគេនៃការពង្រីកនៅក្នុងទីផ្សារប្រទេសមានសេដ្ឋកិច្ចអភិវឌ្ឍន៍មធ្យមផ្សេងទៀតដូចជាមីយ៉ាន់ម៉ា ឡាវ និងប្រទេសវៀតណាម កម្ពុជាបានពិនិត្យផងដែរពាក់ទងនឹងផលប៉ះពាល់ពីការធ្លាក់ចុះសេដ្ឋកិច្ចរបស់ប្រទេសចិន។ មានន័យថាវាស្ទើរតែគ្មានផលប៉ះពាល់សោះមកលើសេដ្ឋកិច្ចកម្ពុជា។

របាយការណ៍បានបង្ហាញថា៖ “ ប្រទេសឡាវ កម្ពុជា និងវៀតណាមបានទទួលអត្ថប្រយោជន៍ ( ពីការធ្លាក់ចុះសេដ្ឋកិច្ចរបស់ប្រទេសចិន ) ខណៈក្រុមហ៊ុននៅប្រទេសឥណ្ឌូនេស៊ី ថៃ និងសិង្ហបុរី ស្ថិតក្នុងចំណោមអ្នកទទួលរងផលប៉ះពាល់អវិជ្ជមានខ្លាំងបំផុត” ៕

**RFA 30/7/16**